MDH Minnesota Department of Health

TUBERCULOSIS (TB) PREVENTION AND CONTROL PROGRAM

# ការព្យាបាលមេរោគជំងឺរបេង (TB) ដែលសំងំក្នុងខ្លួនដោយថ្នាំ Rifampin

ការធ្វើតេស្តរបស់អ្នកបង្ហាញថាអ្នកមានផ្ទុកមេរោគរបេងដែលសំងំក្នុងខ្លួន ឬ LTBI ។ នេះមានន័យថាមេរោគរបេងគឺមាននៅក្នុងខ្លួនរបស់អ្នក និងអាចធ្វើឱ្យអ្នកឈឺបាន។

មេរោគរបេងមិនធ្វើឲ្យអ្នកឈឺចាប់ និងមិនអាចឆ្លងទៅមនុស្សផ្សេងទៀតទេ។ វាហាក់បីដូចជាមេរោគកំពុងតែដេកលក់។ ប្រសិនបើមេរោគរបេងភ្ញាក់ឡើង វាអាចធ្វើឱ្យអ្នកឈឺ។ នេះគេហៅថាជំងឺរបេងសកម្ម។ អ្នកអាចចម្លងមេរោគជំងឺរបេងទៅមនុស្សផ្សេងទៀតប្រសិនបើអ្នកមានជំងឺរបេងសកម្ម។

## តើខ្ញុំអាចបង្ការជំងឺរបេងសកម្មបានយ៉ាងដូចម្តេច?

អ្នកអាចប្រើថ្នាំដើម្បីបង្ការការកើតជំងឺរបេងសកម្ម។ Rifampin គឺជាថ្នាំទូទៅដែលគេប្រើសម្រាប់ព្យាបាលជំងឺ LTBI ។ ថ្នាំនេះសម្លាប់មេរោគរបេងដែលកំពុងដេក មុនពេលវាធ្វើឱ្យអ្នកឈឺ។ អាចចំណាយពេលច្រើនខែដើម្បីសម្លាប់មេរោគរបេងពីព្រោះវាគឺជាមេរោគខ្លាំង។

លេបថ្នាំ Rifampin តាមការណែនាំរបស់គ្រូពេទ្យ ឬគិលានុបដ្ឋាករបស់អ្នក។ ការលេបថ្នាំដោយមិនបានទទួលទានអាហារគឺជាវិធីល្អបំផុត។ ប្រសិនបើអ្នកឆ្អល់ពោះ យល់ល្អលេបថ្នាំជាមួយនឹងអាហារក្នុងបរិមាណតិចតួច ឬព្យាយាមលេបថ្នាំនេះនៅពេលចូលគេង។

## ហេតុអ្វីបានជាខ្ញុំគួរតែលេបថ្នាំប្រសិនបើខ្ញុំមិនមានអារម្មណ៍ឈឺ?

មេរោគរបេងដែលកំពុងដេកគឺងាយស្រួលសម្លាប់ជាងមុនពេលដែលវាភ្ញាក់ឡើង និងធ្វើឱ្យអ្នកឈឺ។




## ចុះបើខ្ញុំមិនលេបថ្នាំ?

បើសិនជាអ្នកមិនលេបថ្នាំ Rifampin ខកខានជាច្រើនថ្ងៃ ឬឈប់ប្រើថ្នាំមុនពេលដែលគ្រូពេទ្យឬគិលានុបដ្ឋាករបស់អ្នកប្រាប់អ្នក អ្នកអាចមានជំងឺរបេងសកម្ម។ វាជាការសំខាន់ដែលត្រូវសម្លាប់មេរោគរបេងដូច្នេះអ្នកនិងគ្រួសាររបស់អ្នកមានសុខភាពល្អ។

## ចុះបើខ្ញុំបានចាក់ថ្នាំវ៉ាក់សាំង BCG?

ថ្នាំវ៉ាក់សាំង BCG ការពារកុមារមិនឲ្យកើតជំងឺរបេងធ្ងន់ធ្ងរ ប៉ុន្តែបានត្រឹមតែរយៈពេលពីរបីឆ្នាំប៉ុណ្ណោះ។ វាមិនអាចការពារកុំឲ្យកើតជំងឺ LTBI ឬជំងឺរបេងសកម្ម។ ប្រសិនជាអ្នកបានចាក់វ៉ាក់សាំង BCG អ្នកគួរតែលេបថ្នាំព្យាបាលជំងឺ LTBI ដើម្បីការពារខ្លួនអ្នក និងអ្នកដទៃ។

## ចុះបើខ្ញុំមិនមានលទ្ធភាពបង់ប្រាក់សម្រាប់ថ្នាំ Rifampin?

សាកសួរគ្រូពេទ្យ ឬគិលានុបដ្ឋាករបស់អ្នកអំពីការទទួលបានថ្នាំរបេងឥតគិតថ្លៃពីកម្មវិធីរបេងរបស់ក្រសួងសុខាភិបាលនៃរដ្ឋមីនីសូតា។

## ចុះបើខ្ញុំបានផ្លាស់ទីទៅឆ្ងាយ?

សូមប្រាប់គ្រូពេទ្យរបស់អ្នកមុនពេលដែលអ្នកផ្លាស់ទីទៅរដ្ឋ ឬទីក្រុងផ្សេងទៀត។ ពួកគេអាចជួយអ្នកបន្តទទួលបានថ្នាំរបេងបន្ទាប់ពីអ្នកបានផ្លាស់ទី។

## គួរតែដឹងអ្វីខ្លះអំពីការប្រើថ្នាំ LTBI?

- កុំផឹកស្រាបៀរ ស្រាក្រហម ឬស្រាវរហូតដល់អ្នកបញ្ចប់ការព្យាបាល LTBI របស់អ្នក។ ការទទួលទានគ្រឿងស្រវឹងក្នុងខណៈពេលប្រើថ្នាំ LTBI អាចប៉ះពាល់ដល់ថ្លើមរបស់អ្នក។
- ប្រាប់គ្រូពេទ្យអំពីថ្នាំដទៃទៀតដែលអ្នកកំពុងប្រើប្រាស់។
- ប្រើប្រាស់វិធីពន្យារកំណើតដូចជាស្រោមអនាម័យជាដើមដើម្បីបង្ការកុំឲមានផ្ទៃពោះ។ ថ្នាំ Rifampin អាចឲ្យការពន្យារកំណើតតាមអ័រម៉ូនមិនមានប្រសិទ្ធភាព។ ហៅទូរស័ព្ទទៅវេជ្ជបណ្ឌិត ឬគិលានុបដ្ឋាករបស់អ្នកភ្លាមប្រសិនបើអ្នកមានផ្ទៃពោះ។

**មនុស្សភាគច្រើនលេបថ្នាំ Rifampin ដោយគ្មានបញ្ហា។ មនុស្សមួយចំនួនពិតជាមានបញ្ហាដូចជា៖**

- គ្រុនអស់រយៈពេលជាងបីថ្ងៃ
- ហូបមិនសូវបាន ឬមានអារម្មណ៍អស់កម្លាំង
- ឈឺក្រពះ និងក្អួត
- មានការឈឺចាប់ត្រង់ពោះ
- ទឹកនោមពណ៌ក្រមៅ (ពណ៌តែ ឬកាហ្វេ)
- ស្បែក ឬភ្នែកពណ៌លឿង
- កន្ទួលស្បែកឬរមាស់
- ស្ពឹក ឬឈឺស្រពន់ដៃឬជើង

**ប្រសិនបើអ្នកមានបញ្ហាទាំងនេះ៖**

1. បញ្ឈប់ការប្រើថ្នាំរបស់អ្នក។
2. ហៅទូរស័ព្ទទៅវេជ្ជបណ្ឌិត ឬគិលានុបដ្ឋាករបស់អ្នកជាបន្ទាន់។ កុំរង់ចាំការណាត់ជួបបន្ទាប់របស់អ្នក។

**ត្រូវចងចាំលេបថ្នាំរបេងរបស់អ្នកជានិច្ច។** ប្រសិនបើអ្នកខកខានជាច្រើនថ្ងៃ ថ្នាំនេះអាចមិនមានប្រសិទ្ធភាព។

- ខាងក្រោមនេះជាវិធីមួយចំនួនដើម្បីជាជំនួយដល់ការចងចាំ៖
- រក្សាទុកថ្នាំ Rifampin របស់អ្នកនៅទីកន្លែងណាដែលអ្នកអាចមើលឃើញ។
- លេបថ្នាំ Rifampin របស់អ្នកនៅអំឡុងពេលតែមួយ។ ឧទាហរណ៍បន្ទាប់ពីអ្នកដុសធ្មេញហើយ ឬមុនពេលអ្នកចូលគេង។
- ស្នើសុំនរណាម្នាក់ជួយរំលឹកអ្នក។
- គូសសម្គាល់លើប្រតិទិនរបស់អ្នកបន្ទាប់ពីអ្នកលេបថ្នាំ Rifampin របស់អ្នក។
- បិទប្រដាសរំលឹក ឬដាក់សំឡេងរោទិ៍ក្នុងទូរស័ព្ទដៃរបស់អ្នក។
- ប្រើប្រអប់រំលឹកលេបថ្នាំ។

ប្រសិនបើអ្នកខកខាននៅថ្ងៃណាមួយ ត្រូវតែកត់ត្រាទុកដូច្នេះអ្នកអាចប្រាប់គ្រូពេទ្យ ឬគិលានុបដ្ឋាករបស់អ្នកនៅពេលណាត់ជួបលើកក្រោយរបស់អ្នក។

**រក្សារាល់ការណាត់ជួបគ្រូពេទ្យរបស់អ្នក។** គ្រូពេទ្យរបស់អ្នក នឹងជួយធ្វើឱ្យប្រាកដថា ការព្យាបាលរបស់អ្នកនឹងដំណើរការបានល្អ

ការណាត់ជួបបន្ទាប់របស់ខ្ញុំទាក់ទិននឹងថ្នាំរបេង៖

កាលបរិច្ឆេទ៖

ពេលវេលា៖

គ្រូពេទ្យ ឬគិលានុបដ្ឋាក៖

ទីតាំង៖

Minnesota Department of Health
Tuberculosis (TB) Prevention and Control Program
P.O. Box 64975, St. Paul, MN 55164-0975
651-201-5414
www.health.state.mn.us/tb